YUNNAN DAILY PRESS GROUP
No.129

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 25 លេខ 7467 ថ្ងៃសុក្រ ទី 27 ខែ តុលា ឆ្នាំ 2017

# ចាប់អារម្មណ៍ចំពោះសមាជបក្សកុម្មុយនិស្តចិន លើកទី១៩បង្កើតសហគមន៍រួមវាសនាមនុស្សជាតិ

*អ្នករៀបរៀងៈកាលពីថ្ងៃទី ១៨ ដល់ទី ២៤ ខែតុលា ឆ្នាំ ២០១៧សមាជ បក្សកុម្មុយនិស្តចិនលើកទី ១៩ ប្រារព្ធធ្វើ នៅក្នុងទីក្រុងប៉េកាំង ។ លោក ស៊ី ជីនភីងបានធ្វើរបាយការណ៍ក្នុងពិធី បើកសម័យប្រជុំថា ប្រទេសចិននឹងប្រកាន់ខ្ជាប់នូវមាគ៌ាអភិវឌ្ឍន៍ដោយ សន្តិភាពជំរុញការបង្កើតសហគមន៍រួម វាសនាមនុស្សជាតិ និងគំនិតផ្តួចផ្តើម ពាក់ព័ន្ធផ្សេងៗ ។ អ្នកនយោបាយ បរទេសអ្នកសារព័ត៌មាននិស្សិតបរទេសដែលបន្តវិជ្ជានៅក្នុងប្រទេសចិន និងគ្រប់មជ្ឈដ្ឋានក្នុងសង្គមបានចាប់អារម្មណ៍យ៉ាងខ្លាំង និងបានថ្លែងមតិចំពោះគំនិតផ្តួចផ្តើមនេះ ។ ពេលនេះយើងខ្ញុំសូមបង្ហាញជូនលោកអ្នកអំពីខ្លឹម សារសំខាន់ៗនៃសមាជបក្សកុម្មុយនិស្ត ចិនលើកទី១៩នេះ ផ្តោតអារម្មណ៍ ទៅលើការបង្កើតសហគមន៍រួមវាសនា មនុស្សជាតិដោយរួមជាមួយលោកអ្នក និងចែករំលែកគ្នាជាមួយលោកអ្នកអំពីទស្សនៈដ៏អស្ចារ្យរបស់ភាគីនានា ៕*



*កាលពីថ្ងៃទី១៨ ខែតុលា សមាជបក្សកុម្មុយនិស្តចិនលើកទី១៩ បើកសម័យប្រជុំនៅក្រុងប៉េកាំង ឯកឧត្តម ស៊ី ជីនភីង អគ្គលេខាធិការនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយ-និស្តចិន បានអញ្ជើញធ្វើដំណើរសំដៅទៅកាន់វេទិកាដើម្បី ថ្លែងរបាយការណ៍ទៅអង្គសមាជ បក្សកុម្មុយនិស្តចិនលើទី១៩ (រូបថត ស៊ីនហួ)*

## អ្នកនយោបាយបរទេសកោតសរសើរចំពោះសមាជបក្សកុម្មុយនិស្តចិនលើកទី១៩នៅពាក់កណ្តាលខែតុលា

ប្រជាជនទូទាំងពិភពលោកចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះទិសបូព៌ានៃពិភពលោកយើង ។ ក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅនោះគណៈបក្សកុម្មុយនិស្តចិនបានដឹកនាំប្រទេសចិនឱ្យទទួលបានសមិទ្ធផលជាផ្លែផ្កា តាមរយៈទស្សនៈ និងរបបនៃការគ្រប់គ្រងប្រទេសដ៏ត្រឹមត្រូវ ។ សព្វថ្ងៃ មានប្រទេសកាន់តែច្រើនវាយពិន្ទុខ្ពស់ឱ្យគណៈបក្សកុម្មុយនិស្តចិន និងវាយតម្លៃខ្ពស់ចំពោះអភិបាលកិច្ចរបស់លោក ស៊ី ជីនភីង និងសមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ នេះ ។

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជាមានប្រសាសន៍ថា ខ្ញុំចាប់អារម្មណ៍ខ្លាំងចំពោះទ្រឹស្តី"សុបិនចិន" "អភិបាលកិច្ចចិន" "ការធ្វើកំណែទម្រង់ស៊ីជម្រៅ" "នីតិរដ្ឋ" "គោលនយោបាយប្រឆាំងនឹងអំពើពុករលួយ" និង"មាគ៌ាអភិវឌ្ឍន៍ដោយសន្តិភាព" ដែលលើកឡើងដោយលោក ស៊ី ជីនភីង ។

លោក សូណេល បូរ៉ាត់ អនុប្រធានគណបក្សស្នេហាជាតិប្រទេសតួកគីបានកោតសរសើរចំពោះក្តីក្លាហានរបស់គណបក្សកុម្មុយនិស្តចិនក្នុងការធ្វើកំណែទម្រង់ផ្ទាល់ខ្លួនថា គណបក្សកុម្មុយនិស្តចិនបានអនុវត្តន៍យុទ្ធនាការប្រឆាំងនឹងអំពើពុករលួយ ដែលបានប្រើកម្លាំងខ្លាំងបំផុតមិនធ្លាប់មានពីមុនពិតជាគួរឱ្យកោតសរសើរជាខ្លាំង ។

លោក សេលកេ ហ្សេលេជីនីយ៉ាក អគ្គលេខាធិការរងនៃគណៈ-កម្មាធិការគណបក្សរួបរួមជាតិរុស្ស៊ី និងជាសមាជិករដ្ឋសភារុស្ស៊ី បានវាយតម្លៃថា ក្នុងនាមជាគណបក្សកាន់អំណាច គណបក្សរួមរួមជាតិរុស្ស៊ីយកចិត្តទុកដាក់កម្រិតខ្ពស់ និងសិក្សាស្រាវជ្រាវដោយលម្អិតអំពីប្រព័ន្ធគ្រប់គ្រងដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងភាពតឹងរ៉ឹងរបស់គណបក្សកុម្មុយនិស្តចិន ។ វិធានការមួយចំនួនធំសម្រាប់ប្រឆាំងនឹងអំពើពុករលួយរបស់ប្រទេសចិនកំពុងតែដំណើរការអនុវត្តន៍នៅក្នុងប្រទេសរុស្ស៊ី ។

លោក សារ៉ះ អាហ្សីល អគ្គលេខាធិការគណបក្សកុម្មុយនិស្តអេហ្ស៊ីប មានប្រសាសន៍ថា ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់គណបក្សកុម្មុយ-និស្តចិនប្រទេសចិនបានទទួលឯករាជ្យ-ជាតិពិតប្រាកដ និងបានត្រួសត្រាយផ្លូវអភិវឌ្ឍន៍ទំនើបមួយខ្សែ ដែលមានលក្ខណៈខុសគ្នានឹងប្រទេសមូលធននិយម ហើយបានក្លាយទៅជាទង់ជ័យនៃចលនាសង្គមនិយមលើពិភពលោក៕

## "Super open class" របស់គណបក្សកុម្មុយនិស្តចិន

រសៀលថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១៧ លោក ម៉ូហានមេត សាមីរ អ្នកសារព័ត៌មានប៉ាគីស្ថាន បានប្រញាប់ត្រឡប់ទៅខុនដូទំនាក់ទំនងការទូតក្រុងប៉េកាំង ដែលជាផ្ទះបណ្តោះអាសន្ននៅក្រុងប៉េកាំងរបស់លោក ។ លោកសង្ឃឹមថា នឹងអាចសរសេរអត្ថបទព័ត៌មានអំពីរបាយការណ៍សមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ ដែលមានអក្សរជាង ៣ ម៉ឺនតួនោះ ដើម្បីចុះផ្សាយជូនមិត្តអ្នកអានប៉ាគីស្ថានក្នុងពេលឆាប់ៗ។

នៅព្រឹកថ្ងៃដដែលនោះ សមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ បានបើកសម័យប្រជុំជាផ្លូវការ ដែលបានទទួលការចាប់អារម្មណ៍ពីពិភពលោកទាំងមូល។ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសំខាន់ៗនៃបណ្តាប្រទេសនានាបានចាប់អារម្មណ៍ និងផ្តោតសំខាន់ទៅលើ របាយការណ៍ដែលធ្វើដោយលោក ស៊ី ជីនភីង ។

លោកម៉ូហានមេត សាមីរ បានប្រាប់អ្នកកាសែតថានេះជា"Super open class" ដែលផ្តល់ដោយគណបក្សកុម្មុយនិស្ត-ចិន ។ លោកបានសិក្សាស្រាវជ្រាវ យ៉ាងស៊ីជម្រៅអំពីរបាយការណ៍របស់ លោក ស៊ី ជីនភីង ដោយឈរលើជំហរពិសេសផ្ទាល់ខ្លួនហើយបានរកឃើញទស្សនៈដ៏មានតម្លៃមួយចំនួនសម្រាប់ដោះស្រាយបញ្ហាប្រឈមរបស់ ប្រទេសប៉ាគីស្ថាន ។

លោកបានគូសបញ្ជាក់ថា ប្រទេសប៉ាគីស្ថានមានខេត្តធំចំនួន ៤ ដែលបានជួបនឹងបញ្ហាអតុល្យភាពក្នុងការអភិវឌ្ឍ ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍សម្របសម្រួលតាមតំបន់ដែលលើកឡើងក្នុងរបាយការណ៍នេះ គឺជាទស្សនៈអភិវឌ្ឍន៍ដ៏សំខាន់ ពីព្រោះយុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយមានតុល្យភាពបែបនេះបានបង្កប់នូវទស្សនៈអភិវឌ្ឍន៍ដោយចែករំលែកគ្នា ។

លោក ស៊ីម៉ន់ ហ៊ីលតុន និពន្ធនាយកផ្នែកអន្តរជាតិនៃ"កាសែតវេទិកាកាមេរូន" មានចំណាប់អារម្មណ៍ខ្លាំងចំពោះសារសំខាន់នៃការរក្សាស្មារតីកំណែទម្រង់ និងច្នៃប្រឌិត ក្នុងដំណើរអភិវឌ្ឍន៍យ៉ាងឆាប់រហ័សរបស់ពិភព-លោកយើង ។ លោកបានបញ្ជាក់ថា តាមរបាយការណ៍នេះបានឱ្យដឹងថា ៥ ឆ្នាំចុងក្រោយនេះ ប្រទេសចិនខិតខំជំរុញការធ្វើកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ និងទូលំទូលាយ ដោយបានចាត់វិធានការកំណែទម្រង់ចំនួនជាង ១៥០០ ។ នេះគឺជាស្មារតីកំណែទម្រង់ និងច្នៃប្រឌិត ៕

**ដោយ ឃឹ ស៊្វីហុង**
**(ទីភ្នាក់ងារ ព័ត៌មានស៊ីនហួចិន)**

## ប្រព័ន្ធផ្សព្វផ្សាយចិន និងបរទេសចាប់អារម្មណ៍ចំពោះការអភិវឌ្ឍដោយផ្ទោះរំលងរបស់ខេត្តយូនណាន

ព្រឹកថ្ងៃទី១៩ ខែតុលា តំណាងខេត្តយូនណានដែលចូលរួមក្នុងសមាជបក្សកុម្មុយនីស្តចិនលើកទី១៩ បានជួបជុំគ្នា និងរៀបចំកិច្ចប្រជុំពេញអង្គនៅក្នុងសាលប្រជុំខេត្តយូនណាននៃវិមានសភាប្រជាជនចិនក្នុង The layout of this week ក្រុងប៉េកាំង ដើម្បីពិគ្រោះពិភាក្សាគ្នាអំពីរបាយការណ៍ការងារនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន នីតិកាលទី១៨ ដែលធ្វើដោយលោក ស៊ី ជីនភីង ។ កិច្ចប្រជុំនេះបើកចំហចំពោះប្រព័ន្ធផ្សព្វផ្សាយជាតិនិង អន្តរជាតិ ។ អ្នកសារព័ត៌មានជាង៦០នាក់ ដែលមកពីអង្គភាពផ្សាយព័ត៌មានចិន និងបរទេសចំនួនជាង៤០អង្គភាពបានចូលរួមយកបទសម្ភាសន៍ក្នុងកិច្ចប្រជុំនេះ ។



*កាលពីថ្ងៃទី១៩ ខែតុលា លោកឆឹន ហាវ លេខាធិការគណបក្សកុម្មុយនិស្តចិនប្រចាំខេត្តយូនណាន (រូបទី៣ខាងឆ្វេង) និងលោកយាន់ ឈឺងហ្វា អភិបាលខេត្តយូនណាន (រូបទី៤ ខាង ឆ្វេង) បានផ្តល់បទសម្ភាសន៍ជាមួយអ្នកសារព័ត៌មានជាតិនិងអន្តរជាតិ (រូបថតដោយ ឡី ធុងស៊្វី)*

លោក ឆឹន ហាវ លេខាបក្សនៃគណៈកម្មាធិការគណបក្សកុម្មុយនីស្ត-ចិន ខេត្តយូនណាន និងជាប្រធានក្រុមអ្នកតំណាងខេត្តយូនណានលោកយាន់-ឈឹងហ្វា អនុលេខាបក្ស នៃគណៈកម្មាធិការគណបក្សកុម្មុយនីស្តចិនខេត្តយូនណាន អភិបាលខេត្ត យូនណាន និងជាអនុប្រធានក្រុមអ្នកតំណាងខេត្តយូនណាន បានឆ្លើយសំណួររបស់ អ្នក-សារព័ត៌មានអំពីការអភិវឌ្ឍដោយផ្ទោះរំលងការគ្រប់គ្រងទីផ្សារទេស-ចរណ៍ការកាត់បន្ថយភាពក្រីក្រ និងការការពារបរិស្ថានបឹង អឺហៃជាដើម ។

អ្នកសារព័ត៌មានមកពី "កាសែត តាកុង ដេលី" តំបន់ហុងកុង បានសួរសំណួរថាតើខេត្តយូនណានត្រូវធ្វើដូម្តេចដើម្បីបញ្ចេញឧត្តមភាពរបស់ខ្លួនសម្រាប់ជំរុញការកសាងសង្គមធូរធារដោយព្រមជាមួយតំបន់ផ្សេងៗក្នុងប្រទេសចិន ហើយសម្រេចបាននូវគោលដៅដែល "បក្សីខ្សោយហើរមុនគេ" "បក្សីខ្សោយហើរបានឆាប់" និងសម្រេចបាននូវការអភិវឌ្ឍដោយផ្ទោះរំលង ។ លោក ឆឹន ហាវ បានឆ្លើយថា ខេត្តយូនណានមានទីតាំងភូមិសាស្ត្រដ៏មានឧត្តមភាព ដោយផ្អែកលើទីផ្សារចិនដ៏ធំដែលមានប្រជាជន ១.៣០០លាននាក់ និងទីផ្សារអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ដែលមានប្រជាជន២.៣០០លាននាក់ ។ ខេត្តយូនណានស្ថិតនៅចំណុចប្រសព្វគ្នានៃទីផ្សារធំទាំងពីរ ដែលបានផ្តល់ចន្លោះទូលំទូលាយសម្រាប់ជំរុញការអភិវឌ្ឍដោយផ្ទោះរំលង ។ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ដោយផ្ទោះរំលង យើងត្រូវបំបាត់ទស្សនៈអន់ថយមួយចំនួនរបស់កម្មាភិបាលនិងមហាជន ដូចជា "បិទទ្វារមិនចេញទៅក្រៅ" និង "បានការរីកចម្រើនតិចតួចក៏បញ្ឈប់ដំណើរទៅមុខ" ជាដើម ហើយត្រូវជំរុញការអភិវឌ្ឍដោយផ្ទោះរំលង និងផ្លាស់ទម្រង់អភិវឌ្ឍន៍ តាមរយៈទស្សនៈអភិវឌ្ឍន៍ថ្មីដែលប្រកបទៅដោយភាពច្នៃប្រឌិត ការសម្របសម្រួល ពណ៌បៃតង លក្ខណៈបើកទូលាយ និងគំនិតចែករំលែកគ្នា ។ ម្យ៉ាងទៀត ប៉ុន្មានឆ្នាំនេះ ខេត្តយូនណានខិតខំពន្លឿនដំណើរសមាហរណកម្មការសិក្សាស្រាវជ្រាវ និងឧស្សាហកម្ម និងជំរុញយ៉ាងសកម្មឱ្យលទ្ធផលសិក្សាស្រាវជ្រាវក្លាយទៅជាសមិទ្ធផលអភិវឌ្ឍន៍ជាក់-ស្តែង ផ្តោតសំខាន់ទៅលើការទាក់ទាញធនធានមនុស្សបច្ចេកវិជ្ជាបែបច្នៃប្រឌិតថ្មី និងគម្រោងវិនិយោគបច្ចេកទេសថ្មី និងកម្រិតខ្ពស់ ជំរុញការអភិវឌ្ឍវិស័យព័ត៌មានវិទ្យា ផលិតកម្មឱសថជីវសាស្ត្រ ផលិតកម្មគ្រឿងបរិក្ខារជឿនលឿន និងឧស្សាហកម្មយុទ្ធសាស្ត្រថ្មីនិងទំនើបមួយចំនួនទៀត ដើម្បីគាំទ្រការអភិវឌ្ឍដោយផ្ទោះរំលង ។

អ្នកសារព័ត៌មានមកពី "កាសែតប្រជាជន ដេលី" បានលើកសំណួរថាតើខេត្តយូនណានបានចាត់វិធានការអ្វីខ្លះ ដើម្បីជំរុញការផ្លាស់ទម្រង់ និងការអភិវឌ្ឍរបស់វិស័យទេសចរណ៍ សម្រាប់គ្រប់គ្រងសណ្តាប់ធ្នាប់ទីផ្សារទេសចរណ៍ឱ្យមានភាពល្អប្រសើរឡើងវិញ ? លោក យាន់ ឈឹងហ្វា បានឆ្លើយថា ខេត្តយូនណានកំពុងខិតខំជំរុញការផ្លាស់ទម្រង់អភិវឌ្ឍន៍នៃវិស័យទេសចរណ៍ ហើយធ្វើឱ្យវិស័យទេសចរណ៍ទទួលបានការរីកចម្រើនយ៉ាងល្អប្រសើរ ។ ខេត្តយូនណានបានចាត់វិធានការចំនួនបី គឺ ទី១-ខិតខំអភិវឌ្ឍន៍វិស័យទេសចរណ៍នៅតំបន់នានាក្នុងខេត្តយូនណានទាំងមូល ហើយជំរុញការផ្លាស់ទម្រង់ និងការអភិវឌ្ឍនៃហេដ្ឋារចនាសម្ព័ន្ធទេស-ចរណ៍ ផលិតផលទេសចរណ៍ និងទីដៅទេសចរណ៍ ។ ទី២-បង្កើត "ប្រព័ន្ធទេសចរណ៍ដែលមានលក្ខណៈវៃឆ្លាត" ហើយបង្កើនល្បឿននៃការអនុវត្តគម្រោង "ប្រើទូរស័ព្ទតែមួយគ្រឿងទៅដើរលេងខេត្តយូនណានទាំងមូល" ។ ទី៣-លើកកម្ពស់ដោយគ្រប់ជ្រុងជ្រោយនូវកម្រិតថ្នាក់នៃការគ្រប់គ្រង និងការផ្តល់សេវាកម្ម ហើយជំរុញការស្ថាបនា "ប្រព័ន្ធឌីជីថល" ដើម្បីដោះស្រាយបញ្ហាប្តឹង និងករណីមិនពេញចិត្តរបស់ទេសចរឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ៕

## ប្រទេសចិនបើកទូលាយធ្វើឱ្យនិស្សិតបរទេសកាន់តែច្រើនដើរចូលក្នុងប្រទេសចិន

លោក ជា តិចហុក ជានិស្សិតខ្មែរម្នាក់ ដែលមកបន្តវិជ្ជានៅក្នុងប្រទេសចិន ។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០១៧ សមាជបក្សកុម្មុយនីស្តចិនលើកទី១៩ បានបើកសម័យប្រជុំនៅក្នុងក្រុងប៉េកាំង ។ លោក និងមិត្តរួមបន្ទប់របស់លោកបានបបួលគ្នាទស្សនាកម្មវិធីទូរទស្សន៍ផ្សាយផ្ទាល់អំពីពិធីបើកសម័យប្រជុំនេះ។ នៅពេលលោក ស៊ី ជីនភីង លើកឡើងអំពី "ការបង្កើតនិម្មាបនកម្មថ្មីសម្រាប់ជំរុញការបើកទូលាយគ្រប់ជ្រុងជ្រោយ" លោកបានថ្លែងចំណាប់អារម្មណ៍ផ្ទាល់ខ្លួនថា បើគ្មានការបើកចំហរបស់ប្រទេសចិន ខ្ញុំពិតជាគ្មានឱកាសមកបន្តវិជ្ជានៅខេត្តយូនណានទេ ។

ប្រាំឆ្នាំមុន លោកបានធ្វើដំណើរមកដល់ប្រទេសចិន ដើម្បីបន្តការសិក្សានៅក្នុងសាកលវិទ្យាល័យ ។ ក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅនោះ លោកមានការយល់ដឹងកាន់តែច្រើនអំពីភាពអស្ចារ្យរបស់ប្រទេសចិន រួមមានអវកាសយានសញ្ញា "ផានកុង" នាវាមុជទឹកសញ្ញា "ជីវឡុង" កែវយឹត "ភ្នែកមេឃ" និងបច្ចេកទេសវិទ្យាសាស្ត្រទំនើបផ្សេងៗរបស់ប្រទេសចិន ។ ជាពិសេសលោកបានឃើញដោយផ្ទាល់ភ្នែកនូវការប្រែប្រួលរបស់ប្រទេសកម្ពុជា និងចិន ដែលនាំមកដោយគំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ។ ប៉ុន្មានឆ្នាំនេះ ប្រទេសចិនបានផ្តល់ការគាំទ្រនិងជំនួយឧបត្ថម្ភច្រើនដល់ប្រទេសកម្ពុជា ដែលបានធ្វើឱ្យប្រទេសកម្ពុជាទទួលបានការរីកចម្រើនគួរជាទីកត់សម្គាល់ ។ ការអភិវឌ្ឍរបស់ប្រទេសចិនមិនគ្រាន់តែបានផ្តល់ផលប្រយោជន៍ដល់បណ្តាប្រទេសជិតខាងនានាប៉ុណ្ណោះទេ ថែមទាំងបានជំរុញការអភិវឌ្ឍរបស់ពិភពលោកទៀតផង ។

លោកសង្ឃឹមថា រដ្ឋាភិបាលចិននឹងផ្តល់អាហារូបករណ៍កាន់តែច្រើនដល់និស្សិតបរទេសដែលស្រឡាញ់ប្រទេសចិន និងភាសាចិន ។ ចំណេះដឹងដែលពួកគេទទួលបានក្នុងប្រទេសចិន ព្រមទាំងអ្វីៗទាំងអស់ដែលពួកគេមើលឃើញដោយផ្ទាល់ភ្នែកក្នុងប្រទេសចិន សុទ្ធតែជាសម្បត្តិដ៏មានតម្លៃបំផុតក្នុងជីវិតរបស់ពួកគេ ៕ **ដោយ លីវ យ៉ុង**